# ការជួយសង្គ្រោះមនុស្សពុលភ្លាមៗ



## ជាតិផ្សែងពុលចូលតាមដង្ហើម:

ប្រញាប់យកអ្នកដែលពុលមកយកខ្យល់អាកាសជៀសវាងកុំដកដង្ហើមយកផ្សែងពុលចូលទៅក្នុងសួត បើកទ្វារបង្អួច ចំហរឲ្យធំ។ បើអ្នករងគ្រោះឈប់ដកដង្ហើម ត្រូវទូរស័ព្ទលេខ 9-1-1 ភ្លាម។



## ជាតិពុលប៉ះស្បែក:

ត្រូវដោះសំលៀកបំពាក់ ដែលប្រឡាក់ជាតិពុលនោះចេញ រួចលាងស្បែកដែលប្រឡាក់ជាតិពុលដោយបង្ហូរទឹកដាក់ឲ្យបានចំនួន១៥នាទី។ ដុះសាប៊ូថ្នមៗរួចបង្ហូរទឹកលាងម្តងទៀតជាសម្រេច។



## ជាតិពុលចូលភ្នែក:

ចាប់ផ្តើមបង្ហូរទឹកស៊ីនៗលាងភ្នែកភ្លាម បន្តការលាងនេះឲ្យបានចំនួន ១៥នាទី ត្រូវឲ្យអ្នករងគ្រោះព្រិចភ្នែកឲ្យបានច្រើនផងនៅពេលដែលលាងភ្នែក និង កុំបង្ខំចាប់បើកត្របកភ្នែកឲ្យសោះ ត្រូវទូរស័ព្ទទៅមជ្ឈមណ្ឌលទទួលខុសត្រូវខាងជាតិពុល (Poison Control Center)ដើម្បីសុំយោបល់ ឬការណែនាំបន្ថែម។



## ជាតិពុលដែលចូលពោះ:

បើអ្នករងគ្រោះមិនដឹងខ្លួន, ប្រកាច់ ឬ មិនអាចលេបអ្វីបាន សូមទូរស័ព្ទលេខ 9-1-1 ភ្លាម។

<u>ឱសថ ឬថ្នាំ:</u> មិនត្រូវឲ្យថ្នាំអ្វីមុនពេលទទួលបញ្ជា ឬការណែនាំតាមទូរស័ព្ទពីអ្នកឯកទេសឡើយ។

<u>ជាតិគីមី ឬវត្ថុប្រើប្រាស់ក្នុងផ្ទះ</u> បើអ្នករងគ្រោះនៅដឹងខ្លួនហើយអាចលេបអ្វីបាននោះ សូមឲ្យទឹកមួយកែវ (ចំណុះពី ២ទៅ ៨អោន) រួចសូមទូរស័ព្ទទៅមជ្ឈមណ្ឌលទទួលខុសត្រូវខាងជាតិពុលឬវេជ្ជបណ្ឌិតដើម្បីសួរឲ្យដឹងថា តើត្រូវធ្វើឲ្យអ្នករងគ្រោះក្អួតឬទេ?

ត្រូវមានសេរ៉ូម៉្យាងឈ្មោះអាយពីកាក (IPECAC)ប្រចាំក្នុងផ្ទះជានិច្ច (ថ្នាំនេះសម្រាប់ធ្វើឲ្យមនុស្សក្អួត)។ គួរមានថ្នាំនេះយ៉ាងហោចណាស់មួយដបសំរាប់ក្មេងម្នាក់ៗ។ បើគ្មានការណែនាំពីមជ្ឈមណ្ឌលទទួលខុសត្រូវខាងជាតិពុល ឬពីវេជ្ជបណ្ឌិតទេ សូមកុំប្រើថ្នាំនេះឲ្យសោះ។

## ក្រោយពីពេលមានអាសន្នកើតឡើង ត្រូវទូរស័ព្ទទៅ

**1-800-876-4766**

១- នៅពេលដែលខាងការីទូរស័ព្ទចាប់ឆ្លើយសូមប្រាប់ឈ្មោះភាសារបស់លោកអ្នកដែលគេហៅជាភាសាអង់គ្លេស។

២- កុំដាក់ទូរស័ព្ទចុះ អ្នកបកប្រែភាសាម្នាក់នឹងមកនិយាយជាមួយ លោកអ្នកតាមទូរស័ព្ទ។ បើត្រូវការឡានសំរាប់ដឹកអ្នកជម្ងឺ សូមទូរស័ព្ទលេខ 9-1-1